www.khmerpostusa.com
សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA


Soben Pin
Co-Founder & Publisher

Free Copies
Vol. 13. Issue #281
October 17, 2019
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

**ព័ត៌មានសំខាន់ៗខាងក្នុង...**

កាលីហ្វ័រញ៉ា រដ្ឋដំបូងគេបង្អស់ហាមឃាត់ *Page 02*



បោះឆ្នោតនៅឡូវែល ថ្ងៃទី០៥ វិច្ឆិកា *Page 04*


លោក ថាយ ជុន


លោក ដមេនិច ឡាយ

Award-Winning Filmmaker *Page 12*



# MRT PRESENTS CAMBODIAN ROCK BAND

*Please see page 11*

## រោងមហោស្រព MRT ឡូវែល សម្តែងរឿង“ក្រុមតន្ត្រីរ៉កខ្មែរ”

នៅសាលមហោស្រពឡូវែល នឹងមានការសម្តែងល្ខោនរឿង“ក្រុមតន្ត្រីរ៉កខ្មែរ-Cambodian Rock Band” ជាលើកដំបូងបង្អស់ នៅឆ្នេរខាងកើតនៃ សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១៦ តុលា ដល់ថ្ងៃទី១០ វិច្ឆិកា នៅសាលមហោស្រពថ្មី The Nancy L. Donahue Theatre។ តួសម្តែងដោយ ឡូរ៉ង យី។ ដឹកនាំរឿងដោយ ម៉ាទី ឡាយុន បាននាំយកការចងចាំនៃភ្លេងនឹង ចម្រៀងល្បីៗនៃ ឆ្នាំ ១៩៦០-៧០ មានបទរបស់ក្រុម “ដាំង ហ្វ៊ីវើ” -មានបទនាង សេរីសុទ្ធា -មានបទ ស៊ិន ស៊ីសាមុត ឬ រ៉ោយ ហូជាដើម។

យី ជាតួសម្តែងម្នាក់បាននិយាយថា “ដោយសារមានអ្នកសម្តែងស្រស់ៗជាក់ស្តែងយ៉ាងនេះ គឺជាវិធីដ៏ ប្រសើរបំផុត ធ្វើឱ្យសិល្បៈល្ខោនក្លាយទៅជាអ្វីមួយ ដែលគេរកប្រដូចមិនបាន, ហើយម្យ៉ាងទៀត វាធ្វើឱ្យតន្ត្រីមានន័យប្រាកដចេញពីក្នុងខ្លួនមកវិញ ថាតើតន្ត្រីនោះជាអ្វី?”

ជាថ្មីម្តងទៀតសាលមហោស្រពឡូវែល បានយករឿងប្រវត្តិដ៏ផ្អែមល្ហែមនៃកម្ពុជារបស់យុវវ័យ កាលពីជំនាន់មុន ដែលជាប្រវត្តិផ្ទាល់របស់មនុស្សចាស់ជាច្រើន ដែលរស់នៅឡូវែលសព្វថ្ងៃ... គឺជាសំណាងខ្លាំងណាស់ ដែលមានវាសនា នឹងឃើញរឿងរ៉ាវរបស់ខ្លួនសារជាថ្មីនៅសហរដ្ឋអាមេរិក។


សិល្បៈករល្ខោនកំពុងសម្តែងនៅ MRT



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL
សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987
Excellent Service Since 1987
គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា
សូមអរគុណចំពោះការបន្តនូវទំនុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ
Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense
Thank you for your continued confidence
In our office to handle your legal and tax matters.
We look forward to serving you well into the future.
16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# California the first state in the nation to ban the sale of new fur products

By Soben Pin

SACRAMENTO, CA – Governor Gavin Newsom signed into law last week, a sweeping legislation to fight animal cruelty and promote animal welfare. California is the first state in the country to ban the sale of new fur products. Furthermore, the law also states it is "unlawful to manufacture, offer for sale, display for sale, trade, give donate or otherwise distribute a fur product in the state. The prohibition would apply to clothing, handbags, shoes, slippers, hats, or key chains that contain fur and provides for a civil penalty for each violation". This new law would exempt leather, cowhide and shearling. It will go into affect in 2023.

Included in a package of bills to ban the sale of new fur products, the legislation also bans animals used in circus acts such as elephants, bears and tigers, and prohibits hunting, trapping, or killing bobcats in California.

"California is a leader when it comes to animal welfare and today that leadership includes banning the sale of fur," said Governor Newsom. "But we are doing more than that. We are making a statement to the world that beautiful wild animals like bears and tigers have no place on trapeze wires or jumping through flames. Just YouTube the videos showing the cruel way these animals – often stripped from their mothers as babies – are trained to do dangerous tricks. It's deeply disturbing."



# កាលីហ្វ័រញ៉ា រដ្ឋដំបូងគេបង្អស់ហាមឃាត់ការលក់ និងការផលិតផលិតផលរោមសត្វថ្មី

ដោយសុបិន ពិន

សានហ្វ្រានស៊ីស្កូ, កាលីហ្វ័រញ៉ា "កាលពីសប្តាហ៍មុន លោកអភិបាលរដ្ឋ ហ្គាវីន ញ៉ូសុម ( អាវិន New som) បានចុះហត្ថលេខាលើច្បាប់ប្រឆាំងនឹងការរំ



លោភបំពានយ៉ាងឃោរឃៅមកលើសត្វ និងលើកកម្ពស់សុខុមាលភាពសត្វ ។ រដ្ឋកាលីហ្វ័រញ៉ា គឺ ជារដ្ឋដំបូងគេនៅក្នុងប្រទេសដែលធ្វើការហាមឃាត់ការលក់ផលិតផលរោមសត្វថ្មី ។ ជាងនេះទៅទៀតច្បាប់នេះ ក៏បានចែងផងដែរថា "វាគឺជាអំពើខុសច្បាប់ក្នុងការផលិត, ការផ្តល់ជូនសម្រាប់លក់ដូរ, ការដាក់តាំងបង្ហាញសម្រាប់លក់, ការធ្វើការជួញដូរ, ការផ្តល់ជាអំណោយ ឬការចែកចាយផលិតផលរោមសត្វនៅក្នុងរដ្ឋមួយនេះ ។ ការហាមឃាត់នេះ ក៏នឹងអនុវត្ត

តទៅទំព័រទី០៩



# ហាងលក់រថយន្ត ដេវីដ អូតូសែល

## បង្កើតនូវសេចក្ដីស្រលាញ់រាប់អានជាមួយយើងខ្ញុំ






សុភា ដេវីត

•មិនមានក្រេឌីត •មានក្រេឌីតមិនល្អ •គ្មានបញ្ហា!

## David Auto Sales

93 Chelmsford St, Lowell, MA 01851

យើងខ្ញុំមានលក់ និងអាចដឹកជញ្ជូនឡាន ម៉ូតូ គ្រឿង បន្លាស់
និងរបស់ប្រើប្រាស់ផ្សេងៗរបស់លោកអ្នកទៅកាន់ប្រទេសកម្ពុជា
តាមរយៈក្រុមហ៊ុន David Auto Export
ទីតាំងទទួលការដឹកជញ្ជូន គឺស្ថិតនៅផ្លូវលេខ 93 Chelmsford
St. Lowell, MA និងនៅឃ្លាំងរបស់យើងខ្ញុំមានទីតាំងនៅ
Cranston, Rhode Island ។ មកកាន់កន្លែងយើងខ្ញុំ
រឺទូរស័ព្ទសម្រាប់ព័ត៌មានបន្ថែមតាមលេខ

**978-786-7777 | 978-996-2129**

អ្នកលក់រថយន្តជនជាតិខ្មែរតែមួយ
នៅញូ អ៊ីងលិន!

យើងខ្ញុំសូមស្វាគមន៍អតិថិជនថ្មី! នៅហាងលក់ឡានដេវិត យើងខ្ញុំខិតខំធ្វើការយ៉ាងយកចិត្តទុកដាក់បំផុត តាមតម្រូវការរបស់អតិថិជន ដើម្បីទទួលការជឿទុកចិត្តពីអតិថិជនលើសេវាកម្ម និងគុណភាពដែលអតិថិជនចង់បាន។

សូមអរគុណ!
ក្រុមការងារផ្នែកលក់ហាងដេវីត

**បើកលក់ 7 ថ្ងៃក្នុង**
**មួយសប្តាហ៍** 10AM - 7PM

សូមទាក់ទងលោកដេវីត (David) **978-996-2129**





# បោះឆ្នោតនៅឡូវែលថ្ងៃទី៥វិច្ឆិកា នរណាខ្លះជាបេក្ខជន?

ដោយ ពិន សំខុន

បេក្ខជនសមាជិកក្រុមប្រឹក្សាក្រុងនៅសល់១៨រូប បន្ទាប់ពីបានជម្រុះអស់៣នាក់មក ។ បេក្ខជនអាមេរិកាំងដើមកំណើតខ្មែរនៅជាប់ឈ្មោះទាំង៣រូបនៅឡើយ គឺ វ៉ាស្នា នួន ជាប់លំដាប់ថ្នាកលេខ១៦


លោក ថាយ ជុន


លោក ដមេនិច ឡាយ

សុខារី ចៅ ជាប់លំដាប់លេខ៧, នឹង ថាយ ជុំ ចាប់លំដាប់លេខ១២ ។ អ្នកចូលរួមបោះឆ្នោត នាថ្ងៃទី២៤កញ្ញានោះ មានតែចំនួន៩,៩% តែប៉ុណ្ណោះ បានន័យថា អ្នកបោះឆ្នោតជាច្រើនយ៉ាងហោចណាស់ ៣០-៤០%ថែមទៀត មិនទាន់ចេញមកបោះឆ្នោតនៅឡើយ ដែលអាចនឹងប្តូរលំដាប់ថ្នាក់នៃជាប់ឆ្នោត៩នាក់ដំបូងបានយ៉ាងងាយស្រួលនៅជុំទី២ ។

ឱ្យបានច្រើននោះ ត្រូវតែនាំគ្នាទៅបោះឆ្នោតដោយគូសយកឈ្មោះខ្មែរ ឱ្យបានគ្រប់៧គ្នា។ បេក្ខជនខ្មែរថ្មីម្នាក់ ដែលនៅក្មេង ធ្លាប់មានឈ្មោះជាអ្នកបំរើសហគមនិខ្មែរជាប្រចាំនៅមានអនាគតវែងឆ្ងាយដោយមិនមានប្រកាន់បក្ខពួកឬមានប្រឡាក់ពណ៌នយោបាយក្រុមណានៅឡើយ គឺ ថាយ ជុំ គួរតែសហគមន៏ខ្មែរជួយផ្តល់ប្តើមជាងគេ ដល់បេក្ខជននេះពីឥឡូវនេះទៅផង។ **តទៅទំព័រទី ០៥**


REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY
WITH COST EFFECTIVE NEWSPAPER ADVERTISING




PUBLISHING
Two Issues Every Month

READERSHIP
50,000 Monthly
600,000 Annually

Khmer Post USA Distribution Locations Include:
- Households
- Markets
- Retail Businesses
- Restaurants
- Office Buildings
- Government Offices
- Chamber of Commerce
- Buddhist Temples
- Laundromats
- And Much More

| 2019 PRINTING DATES | 2019 PRINTING DATES |
|---|---|
| 7Jan and 21 | 8 July and 22 |
| 4 Feb and 18 | 5 Aug and 19 |
| 4 March and 18 | 9 Sept and 23 |
| 8 April and 22 | 17 Oct and 28 |
| 6 May and 20 | 11 Nov and 25 |
| 10 Jun and 24 | 05 Dec and 19 |

Advertising deadlines are 5 business days prior to printing date.

ADVERTISING RATES AND SIZES
All ads are printed in Full Color

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 5% Savings | 6 Months (12 Issues) 7.5% Savings | 12 Months (24 Issues) 10% Savings |
|---|---|---|---|---|
| Full (10" x 13") | $460 | $2,622 | $5,106 | $9,936 |
| 1/2 (10" x 6.5") | 310 | 1,674 | 3,441 | 6,696 |
| 1/4 (5" x 6.5") | 165 | 940 | 1831 | 3,564 |
| 1/8 (5" x 3.25") | 90 | 513 | 999 | 1,944 |

CONTACT INFO
27 Jackson St. Unit 329 Lowell, MA 01852
Tel: 978.677.7163 • Email: soben@khmerpostusa.com
www.khmerpost.com
10 YEARS
Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau



WANT TO DRIVE FOR THE LRTA?



NOW HIRING
Full-Time Bus Drivers
Part-Time Bus Drivers
CDL-A or CDL-B with
Passenger Endorsement required
Other LRTA requirements may apply
Monday - Sunday
5 Day Work Week • Some Split Shifts
Full-Time Bus Drivers Receive:
Competitive Pay Rate • Medical & Life Insurance
401K • And More!
Please send resume to General Manager at
customerservice@LRTA.com
Or Apply In Person
Lowell Regional Transit Authority
100 Hale Street • Lowell, MA • Mon-Fri: 8 am - 4 pm
978-452-6161 • www.LRTA.com
Lowell Regional Transit Authority
An Equal Opportunity Employer

## តមកពីទំព័រទី ០៤ បោះឆ្នោតនៅឡូវែលថ្ងៃទី០៥ វិច្ឆិកា

យើងសូមជូនសមាសភាពថ្មី ដែលមានរូបភ្ជាប់ជាមួយអត្ថបទនេះ។ នៅលើបេក្ខជនទាំងអស់គេ អាចគូសយកបាន ពី១រូបរហូតដល់៩រូប ។

នៅមានការបោះឆ្នោត"គណៈកម្មកាសាលារៀន" ដែលគេយក៦រូប ក្នុងចំណោម១២រូបដែលឈរឈ្មោះនៅថ្ងៃជាមួយគ្នាមួយទៀត ដែលមិនត្រូវរំលង, ក្នុងនោះមានបេក្ខជនខ្មែរអាមេរិកាំងម្នាក់ដែលឈរឈ្មោះបន្តរទៅអាណត្តិថ្មី២ឆ្នាំទៀត គឺ ដមីនិកឡាយ ដែលធ្លាប់បានបង្ហាញស្នាដៃ នឹងបញ្ចេញសម្លេងច្រើនដងការពារផលប្រយោជន៍សហគមន៍ខ្មែរ ។ក្នុងពេលនោះ គេអាចគូសឈ្មោះបាន ពី១រហូតដល់៦នាក់ បងប្អូនខ្មែរបើហោចណាស់ក៏គូសយក ដមីនីក ឡាយម្នាក់ដែរ ។

នៅមាន"សំនួរប្រជាមតិ"មួយទៀត ដែលគេសុំឱ្យបងប្អូនម្ចាស់ឆ្នោតឆ្លើយ"អំពីរបៀបថ្មីសម្រាប់បោះឆ្នោតក្រុមប្រឹក្សាក្រុងនៅឆ្នាំ២០២០"។ ក្នុងចំណោមមតិ២:

១-ជម្រើសទី១ជាការបោះឆ្នោតតាម "សង្កាត់ -by district" សង្កាត់និមួយ២ ត្រូវជ្រើសយកតំណាងសម្រាប់តំបន់ខ្លួនម្នាក់ ដែលនឹងក្លាយជាសមាជិកក្រុមប្រឹក្សាមកពីសង្កាត់, តំណាងរបៀបនេះមាន ៨រូប+ ដំណាង៣រូបទៀត គឺក្រុងឡូវែលទាំងមូលជាអ្នកបោះឆ្នោតឱ្យ -ចំនួនសមាជិកក្រុមប្រឹក្សាក្រុងនឹងឡើងពី៩រូប ទៅ១១រូបវិញ នៅឆ្នាំ២០២០។ ២-គឺការបោះឆ្នោត"តាមលំដាប់ថ្នាក់-by ranking" គឺចំនួនឆ្នោតបានច្រើនតែនៅចាញ់អ្នកមានលំដាប់ខ្ពស់ច្រើនទៅវិញបាន។ របៀបបោះឆ្នោតចុងក្រោយនេះ វាពិបាកយល់ជាងសំនួរទី១

សម្លេង"ភាគច្រើន"នៃអ្នកឆ្លើយនឹងប្រជាមតិនេះ មិនច្បាស់ជាសាលាក្រុងសម្រេចយកតាមសម្លេងមតិភាគច្រើននោះទេ ពីព្រោះសាលាក្រុងនៅតែអាចកែតម្រូវនូវជម្រើសណាដែលគេមិនចូលចិត្តនោះ ក៏បានដដែល ។

សមាជិកគណកម្មការសាលានឹងបេក្ខជនផង ដមីនីត ឡាយ កាលពីរសៀលទី១២តុលានេះ នៅសាល "សានីដា" លោកបាននិយាយថា មិនបានពេញចិត្តនឹងជម្រើសទាំងពីរ-នេះទេ ដោយគិតថា ជនភាគតិចនឹងមិនបានអាសនៈនៅសាលាក្រុងទេ ពីព្រោះតែក្រុម ស្បែកស គេស្រុះគ្នាចេញទៅបោះឆ្នោតយកចំណេញសម្រាប់តែពួកគេនេះម្យ៉ាង ហើយម្យ៉ាងទៀត គឺការកាត់កងសង្កាត់សារជាថ្មី ខ្ញុំឃើញថានឹងគ្មានយុត្តិធម៌ឱ្យពួកភាគតិចទេ។

រីឯបេក្ខជន ថាយ ជុំ - Ty Chum បានឆ្លើយ តបថា "សំណើរនេះសមរមល្អហើយ គេគួរតែជ្រើសយកមួយ ដែលខ្ញុំយល់ថាជាសំណាងរបស់ជនជាតិភាគ តិចហើយ..." លោកបានបន្តរថា"បើយើងឃើញថា ជាចំណុចមិនទាន់ល្អ យើងត្រូវប្រាប់ពលរដ្ឋ ហើយកែតម្រូវបានពេលក្រោយទៀត...នេះជាភារកិច្ចរបស់យើង"។

តាមទស្សនះយើងយល់ស្របតាម ដមីនីក ឡាយ - Dominic Lay ទាំងស្រុង ដោយសារតែ "ការសួរពីរបៀបបោះឆ្នោត" មិនបានត្រូវភ្ជាប់ជាមួយនៅការ"បែងចែកជាសង្កាត់"ឱ្យហើយជាមុននោះទេ វានឹងជួយ"បំបែកឆ្នោតជនភាគតិច"រឹតតែខ្លាំងមិនអាចឱ្យ"ជនភាគតិច"ជាប់ឆ្នោតថ្ងៃមុខបានទេ។

ប្រជាពលរដ្ឋម្ចាស់ឆ្នោតត្រូវតែគិតពីប្រយោជន៍គ្រួសារខ្លួនឯងក្នុងសហគមន៍ឱ្យបានខ្លាំង ពីព្រោះក្រុម "សាសនីស" គេសកម្មខ្លាំងណាស់ពេលនេះ ពីព្រោះគេត្រូវការឱ្យសង្កាត់ពួកគេ នៅតែឈ្នះជារហូតទៅ។ ដូច្នេះដើម្បីការពារសុវត្ថិភាពនៃតំបន់របស់យើងម្នាក់ៗត្រូវនាំគ្នាស្វែងយល់ពីប្រុងប្រយ័ត្នពីកាងាររបស់សាលាក្រុង ដែលយកប្រាក់ពន្ធដារយើងទាំងអស់គ្នា បែរជាបំរើតែសង្កាត់ណាមួយទៅវិញ។ មិនគួរឱ្យមានរបៀបនេះតទៅមុខទៀតទេ, ក្រុងឡូវែលរបស់យើង ត្រូវតែចែករំលែកធុនធានឱ្យបានស្មើរៗគ្នា,មើលថែពាណិជ្ជកម្មខ្មែរ នឹងរក្សា វប្បធមិ ជនជាតិផ្សេង ក៏ឱ្យស្មើគ្នាដែរ... ។ល។

ដំណឹងពីមជ្ឈមណ្ឌលព្យាបាលជំងឺណស ស៊រ

ការិយាល័យសង្គ្រោះបន្ទាន់
នៅមន្ទីរពេទ្យញញ្ញាន
NSMC នឹងឈប់បិទ
នៅថ្ងៃទី ៣ ខែវិច្ឆិកា

ប្រសិនបើលោកអ្នកមានបញ្ហាសុខភាពបន្ទាន់
បន្ទាប់ពីថ្ងៃទី ៣ ខែវិច្ឆិកា
សូមទូរស័ព្ទទៅកាន់ 911
រឺទៅកាន់

មន្ទីរពេទ្យសាលេម NSMC
3 Dove Avenue
Salem, MA 01970
បើកដំណើរការ 24/7

សម្រាប់ការរងរបួសបន្តិចបន្តួច រឺជំងឺ
ក្អក, មុត រឺរលាក ឬកន្ទួល

ទៅកាន់
មជ្ឈមណ្ឌលថែរក្សាសុខភាពបន្ទាន់ NSMC
500 Lynnfield Street
Lynn, MA 01904
បើកដំណើរការពីម៉ោង ៩ am - ៩ pm

ដើម្បីទទួលបានព័ត៌មានបន្ថែមអំពី
មជ្ឈមណ្ឌលថែរក្សាសុខភាពបន្ទាន់នៅលីន,ចូលទៅកាន់
nsmc.partners.org/healthiernorthshore

NORTH SHORE MEDICAL CENTER
a member of Partners HealthCare




មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare
and Other Health Insurances
Our Staff Speaks Khmer

## IMMIGRATION AND CUSTOMS ENFORCEMENT

### If ICE Agents Show Up At Your Door:

- Don't open the door, but be calm. You have rights.
- Ask what they are there for (and ask for an interpreter if you need one).
- If they ask to enter, ask if they have a warrant **signed by a judge*** and if so, ask to see it (through a window or slipped under the door).
- If they do **NOT** have a warrant **signed by a judge***, you may refuse to let them in. Ask them to leave any information at your door.
- If they force their way in, don't resist. Tell everyone in the residence to remain silent.
- If you are arrested, remain silent and do not sign anything until you speak to a lawyer.

* An ICE administrative warrant (form I-200, I-205) does not allow them to enter your home without your consent.

ACLU **KNOW YOUR RIGHTS**

បកប្រែ និងប្រែសម្រួលជាភាសាខ្មែរក្រៅផ្លូវការដោយ CAM-SCHOLAR GROUP
. Un-official translated into Khmer by CAM SCHOLAR GROUP.

# ការអនុវត្តច្បាប់អន្តោប្រវេសន៍ និងគយ

## ប្រសិនបើភ្នាក់ងារអន្តោប្រវេសន៍ និងគយ (ICE) បង្ហាញខ្លួននៅមុខផ្ទះរបស់អ្នក :



Sanghak Kan, KhmerPost USA
Long Beach Ambassador

- ហាមបើកទ្វារ ប៉ុន្តែរក្សាភាពនឹងន។ ត្រូវដឹងថា អ្នកមានសិទ្ធិ

- ត្រូវសួរថា តើពួកគេមានការអ្វី (និងស្នើសុំឱ្យមានអ្នកបកប្រែ ប្រសិនបើចាំបាច់)

-ប្រសិនបើពួកគេសុំឱ្យបើកទ្វារ សួរថាតើពួកគេមានដីកាឆែកឆេរ ដែលមានចៅក្រមចុះហត្ថលេខាឬទេ ប្រសិនបើពួកគេថាមាន ត្រូវសុំមើល (ហុចតាមបង្អួច ឬស៊កចូលពីក្រោមចន្លោះទ្វារ)

-ប្រសិនបើពួកគេគ្មានដីកាដែលចៅក្រមចុះហត្ថលេខា៩ទេនោះ អ្នកអាចបដិសេធការបើកទ្វារ។ ស្នើពួកគេឱ្យទុកព័តិមានពាក់ព័ន្ធនៅមាត់ទ្វារ។

-ប្រសិនបើពួកគេបង្ខំចូលក្នុងផ្ទះ អ្នកមិនត្រូវរា-រាំងឡើយ។ ប្រាប់មនុស្សគ្រប់រូបក្នុងផ្ទះឱ្យរក្សាភាពស្ងប់ស្ងៀម។

-ប្រសិនបើគេចាប់ខ្លួនអ្នក ត្រូវរក្សាភាពស្ងប់ស្ងៀម និងហាមចុះហត្ថលេខាលើឯកសារណាមួយឱ្យសោះ រហូតបាននិយាយជាមួយមេធាវី។

* ដីការបស់រដ្ឋបាលអន្តោប្រវេសន៍ និងគយ (TRmg; I-200, I-205) មិនអនុញ្ញាតឱ្យពួកគេចូលផ្ទះរបស់អ្នកដោយអ្នកមិនឯកភាពនោះឡើយ។

ACLU ត្រូវដឹងពីសិទ្ធិរបស់អ្នក


ខ្មែរផុស KhmerPost USA

**Now Coming to California!**

The state of California has the highest concentration of Cambodians in the country with over 35% residing in the greater Los Angeles area. According to the Census Bureau, there are **116,822 Cambodians** living in California, **41,459** in Los Angeles County, and **19,784** in the City of Long Beach.

With the expansion in California, **The KhmerPost USA** will bring relevant news and information, in both Khmer and English, in the **free** biweekly newspaper publication. We have the same commitment and dedication to our readers and advertisers that we have provided for the past 10 years to the Cambodian communities in New England.

- New Format! - Monthly Magazine Style
- Local News Relevant to the greater Long Beach Area
- Excellent Advertising Opportunities
- New Completive Rates!
- For additional information call: 714.486.3060

Celebrating 10 Years of Service



**KhmerPost USA, LLC**
**សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក**



**អគ្គនាយក សុបិន្ត ពិន**
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com



**និពន្ធនាយកខ្មែរ** Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com



Richard Howe Jr.
Contributed Writer | Editor

**ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន**
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com

**ច្នៃសោភ័ណ្ឌភាព** Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

# ដំណើរទៅកម្ពុជារបស់លោក សម រង្ស៊ី អាចនឹងជោគជ័យបើ...

"ទស្សនៈនយោបាយខ្មែរ"

-ដោយ ពិន សំខុន

លោក សម រង្ស៊ី មានវិធីសាសន៍ចំឡែកនឹងចេញទៅប្រយុទ្ធនៅពេលដែលរៀបប្រុងចេញដំណើរទៅភ្នំពេញថ្ងៃទី៩វិច្ឆិកា ២០១៩ ដែលប្រកបដោយគ្រោះថ្នាក់នឹងដោយគ្មានការជឿជាត់ ដូចជានៅកម្ពុជាយើងជាដើម។ នៅ២ឆ្នាំចុងក្រោយនេះលោក បានប្រមូលកៀងគរមនុស្សដែលសំខាន់ធ្លាប់មានប្រជា ប្រិយគាំទ្រ"សង្គ្រោះជាតិ" ក្នុងតំបន់នានា (នៅឡូវែល មាន អ៊ុង វីទ្ធី - ប៉ែន សុខផល) ឱ្យមកគាំទ្រលោកតាមរយៈបណ្តាញដែលលោកបានថែររក្សាមិនឱ្យដាច់ខ្សែរយៈ( ក្រុម"CNRP NA"មានជា គឹម លី មាន ពេទ្យ ឆាន ទូច) រួចហើយលោក សម រង្ស៊ី បញ្ជាឱ្យផ្តាច់ខ្លួនចេញពីក្រុម"សង្គ្រោះជាតិ"ចាស់ ទៅបង្កើតជាក្រុមថ្មីមួយឬច្រើនទៀត ដែលស្តាប់បង្គាប់ទីបញ្ជាការរបស់លោកផ្តាច់មុខ។ ហើយរូបភាពនៃកំណើតរចនាសម្ព័ន្ធចំឡែកនេះ បានកើតមាននៅគ្រប់តំបន់នៃអាមេរិក បារាំង កាណាដា កូរ៉េខាងត្បូង... កន្លែងដែលមានចលនាប្រឆាំងរដ្ឋាភិបាល ហ៊ុន សែន ចាប់តាំងពីដើមឆ្នាំ២០១៨មក។

នៅទីបញ្ជាការជាន់ខ្ពស់របស់លោក សម រង្ស៊ី



សម រង្ស៊ី: "ខ្ញុំទៅចាប់ ហ៊ុន សែន..." ព្រះមហាក្សត្រ ជាអាយ៉ង របស់ហ៊ុន សែន, ហ៊ុន ម៉ាណែត សញ្ញាប័ត្រក្លែងក្លាយ

មានលោកស្រីដំណាងរាស្ត្រ ជូឡុង សូមូរ៉ា លោកដំណាងរាស្ត្រ អេង ឆាយអៀង - នៅទីបញ្ជាការជាន់កណ្តាលមានលោកស្រីដំណាងរាស្ត្រ មូរ សុខហួរ លោកដំណាងរាស្ត្រ យឹម សុវណ្ណ លោកដំណាងរាស្ត្រ តុប វ៉ាន់ចាន់, លោកតំណាងរាស្ត្រ អ៊ូ ចាន់រឹទ្ធ។ រីឯមេបញ្ជាការក្រៅប្រទេសមាននៅសហរដ្ឋអាមេរិកគឺលោក ជា គីមលី អមដោយ លោក អ៊ុង វីទ្ធី (ថ្មី) ហើយប្រើប្រាស់បាវចនានៃកងកម្លាំង សង្គ្រោះជាតិ សម រង្ស៊ី គឺ"សម រង្ស៊ី-កឹម សុខា ជាមនុស្សតែមួយ"។

**ភាពរួបរួមគ្នាជាទំនិញដែលរាស្ត្រចូលចិត្ត:**

បាវចនានេះ ជាទំនិញដែលលក់ដាច់(រាស្ត្រចូលចិត្តទិញ) ពីព្រោះទាំងអស់គ្នាយល់ថា"សង្គ្រោះជាតិជាគណបក្សដែលកើតពីការរួបរួមគ្នានៃគណបក្ស ២ គឺ កឹម សុខា-សម រង្ស៊ី តែបែកគ្នាគឺស្លាប់ហើយ"។ ក្រុម សម រង្ស៊ី បានប្រើសម្តីភ"ឃោសនា"ថា "ចង់ខ្លាំងយើងត្រូវរួមគ្នា" ដែលជាបំណងរបស់ កឹម សុខា ធ្វើបានជាកម្លាំង គាំទ្រដោយពលរដ្ឋស្នេហាជាតិនឹងដោយប្រទេសលោកសេរីផង, ក៏ប៉ុន្តែ"ទង្វើ សម រង្ស៊ី" នៅក្រៅប្រទេសខ្មែរនេះ គឺត្រូវតែបំបែក"កម្លាំងដ៏ខ្លាំងក្លារបស់សង្គ្រោះជាតិ"នេះដោយខ្លួនឯង ប៉ុន្តែនេះមិនមែនជាបំណងរបស់សង្គ្រោះជាតិទេ វាជាបំណងរបស់ ហ៊ុន សែន ទៅវិញតែប៉ុណ្ណោះ!!! "ទំនិញដ៏ខ្លាំងក្លា វាលក់បានថ្លៃជាង ទំនិញដែលទន់ខ្សោយ"។

លោកសមរង្ស៊ីធ្លាប់លក់ទំនិញរបៀបនេះយ៉ាងជាក់ស្តែងដំបូងបង្អស់ គឺលក់"សម្ព័ន្ធអ្នកប្រជាធិបតេយ្យដែលកើតនៅបាងកក" **តទៅទំព័រទី០៩**



១៩៩៨ មាតុភូមិនិវត្តន៍របស់អ្នកប្រជាធិបតេយ្យ រូបថតនៅព្រលានយន្តហោះបាងកកដែលគ្មានគណបក្ស សម រង្ស៊ី ទេ


6 មូលហេតុ ដែលត្រូវចូលរួម

- គ្មានការបង់ប្រាក់ជាមុន-រហូតទៅ
- សេវាពេទ្យធ្មេញ ដែលមិនមែនជាចំណាយរបស់អ្នក
- Healthy You Card ដើម្បីទិញ អ្វីខ្លះដែលទាក់ទងនឹងសុខភាព (អ្នកទទួលបាន $100 ក្នុងមួយឆមាស រហូតដល់ $400 ក្នុងមួយឆ្នាំ)
- ចូលជាសមាជិក YMCA ឥតគិតថ្លៃ ចំនួនមួយខែចំពោះ សមាជិកក្លឹបហាត់ប្រាណ $55 ក្នុងមួយខែ
- អត្ថប្រយោជន៍ទាំងអស់នាពេលបច្ចុប្បន្នរបស់អ្នកពីកម្មវិធីម៉ាស់ហិល MassHealth
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព*




SWH SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
1-888-566-3526 (TTY 711)
www.seniorwholehealth.com/SNP
ម៉ោង ៨ ព្រឹកដល់ម៉ោង ៨ យប់7 ថ្ងៃក្នុងមួយសប្តាហ៍។

សូមរក្សាទុកអត្ថប្រយោជន៍ពីកម្មវិធីម៉ាស់ហិល MassHealth របស់អ្នកទាំងអស់ បូកជាមួយអ្វីដែលពួកបន្ថែមចូលទៀត

ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare ផ្នែក A និង/ឬ ផ្នែក B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។

Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលត្រូវបានអនុវត្ត និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។ ជូនដំណឹង៖ ប្រសិនបើលោកអ្នកនិយាយភាសាក្រៅពីភាសាអង់គ្លេស អ្នកអាចប្រើសេវាជំនួយភាសាឥតគិតថ្លៃបាន។ ហៅទូរស័ព្ទមក 1-888-794-7268 (TTY 711)។ ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY 711)។ ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY 711)។ Senior Whole Health (HMO SNP) និង Senior Whole Health NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយសហធនម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ: EOHHS MassHealth។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យារាល់ឆ្នាំ។ ផែនការនេះមានសម្រាប់អ្នកដែលមានអាយុលើសពី 65 ឆ្នាំ ឬចាស់ជាងដែលមានទាំងជំនួយវេជ្ជសាស្ត្រពីរដ្ឋ និង Medicare ឬ Medicaid តែប៉ុណ្ណោះ។ H2224-2018_70986_M_KHM បានអនុម័ត 11/2/2018 *អាចនឹងមានការដាក់កម្រិត

# មណ្ឌលពិនិត្យសុខភាពឡូវែល

## Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
**Sokharith Mey, M.D.**

លោក ចាន់ ទូច , C.N.P.
**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ
***Family Medicine***

&

សុខភាពផ្លូវចិត្ត
***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហ៊ែល, មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking

តមកពីទំព័រទី ០៧

## ដំណើរទៅកម្ពុជារបស់លោក សម រង្ស៊ី.

នៅឆ្នាំ១៩៩៨។សម្ព័ន្ធនោះ មានគណបក្ស៤គឺះ ១-គណបក្សហ្វុនស៊ិនប៉ិច ២-គណ បក្សលោកតាសឺងសាន ៣-គណបក្សខ្មែរអព្យាក្រឹត្យ -នឹង ៣-គណបក្សជាតិខ្មែរ ដែលបានតស៊ូរួមគ្នា ដោយអាវុធនឹងតាម-នយោបាយរយៈពេលពេញមួយ ឆ្នាំពីទីក្រុងបាងកកធ្វើរហូតដល់អង្គការសហប្រជា ជាតិនាំបក្សប្រឆាំងទាំងអស់ឱ្យត្រឡប់យ៉ាងគួរឱ្យមានសង្ឃឹមចូលទៅកម្ពុជាវិញ, ក៏ប៉ុន្តែក្រុមលោក សម រង្ស៊ី - អេង ឆាយអៀង - សូម្ហ៊ូរ៉ា ជូឡុង បានក្បត់ កិច្ចព្រមព្រៀងខ្លួនឯង ចូលទៅទទួលកិច្ចចរចានយោបាយជាបដិសណ្ឋាកិច្ចរបស់លោក ហ៊ុន សែន នៅ មុនមួយថ្ងៃធ្វើឱ្យអ្នកទៅក្រោយបែកបាក់គ្នាមានការអាម៉ាសយ៉ាងខ្លាំង។ នឹងចាញ់ឆ្នោតទាំងអស់គ្នានៅពេលបន្ទាប់មក។

**ដំណើរមាតុភូមិនិវត្តន៍របស់ សម រង្ស៊ី អាចនឹងមានជោគជ័យ បើលោកមានភាគហ៊ុនក្នុងបក្សប្រជាជន**

២០ឆ្នាំក្រោយមក ខ្មែរនៅតែមិនរៀងចាលនៅតែ"ជឿអ្នកមានសម្តីផ្អែមមិនព្រមមើលទង្វើអាក្រក់អ្នកនយោបាយ"ដែលគេហៅថា"អំពើក្បត់ឬបោកប្រាស់" -ដូច្នេះវានឹងបែកបាក់ហើយនឹងចាញ់របបផ្តាច់ការតែដដែល ហើយត្រូវគេបានជេប្រទេចផ្តាសារាល់ថ្ងៃ។

ដើម្បីឈ្នះ លោក សម រង្ស៊ី នឹងបរិវាគួរតែប្តូរយុទ្ធសាស្ត្រត្រូវមើលឃើញខ្លួនឯងថា "បានជួយរបបហ៊ុន សែន ច្រើនណាស់ហើយ គួរតែទាមទារឱ្យលោក ហ៊ុន សែន ទទួលយកលោកដោយចំហរបានហើយ" ឱ្យធ្វើជាផ្នែក១នៃ"បក្សកាន់អំណាច"ជាមួយគេ មិនចាំបាច់លាក់នឹងប្រជាពលរដ្ឋទៀតទេ ហើយក៏មិនចាំបាច់រំលាយគណបក្សប្រឆាំងឱ្យទៅជាផេះធ្វើអ្វីដែរ -ពេលនោះទៅស្រុកខ្មែរវិញ គេអាចទទួលលោកពេញមុខជា"វិរបុរសជាតិធ្វើមាតុភូមិនិវត្តន៏"ទៀតផង - លោក ហ៊ុន សែន ក៏អាចវាយមួយដំបងនេះ ចំពីមុខបក្សប្រឆាំងជាចុងក្រោយបានយ៉ាងដំណំដែរ មិនងាយចេញពីការបាក់ស្បាតបានឆាប់រហ័សទេ - ហើយសហគមន៍អន្តរជាតិដែលបានជួយបក្សប្រឆាំង ក៏ចាញ់ប្រាជ្ញា ហ៊ុន សែន ផងនឹង សម រង្ស៊ី ផងក៏នឹងលែងទុកចិត្តបក្សណាទាំងអស់តែម្តង។



មាតុភូមិនិវត្តរបស់លោក សម រង្ស៊ី អាចនឹងទទួលជោគជ័យ ៩វិច្ឆិកា

តើលោក សម រង្ស៊ី នៅជួយអី ហ៊ុន សែន បានទៀតទេ? គឺ ១-លោក ហ៊ុន សែន នៅចង់បានការប្តូររដ្ឋធម្មនុញ្ញដាក់ខ្លួនជាប្រធានាធិបតីនៅឡើយ, ២-ការលើកដំកើងកូនប្រុសស្រីរបស់គាត់យ៉ាងលឿនយ៉ាងនេះ គឺធ្វើឱ្យមានការធានាថា គឺមានតែកូនប្រុសរបស់លោកនឹងបន្តវំណែងលោកទាំងនៅសភាទាំងនៅរដ្ឋាភិបាលនៅពេលអត់ពី ហ៊ុន សែន ទៅ ។

ឃើញទេ ការងារបោកប្រាស់គេនៅច្រើនទៀតនៅឡើយ! មិនចាំបាច់ទៅធ្វើបាប ឆ្លើយដាក់លោក ស ខេង ឬខ្មោចលោក ជា ស៊ីម មកធ្វើជា"រនុកក្នុង"ឱ្យលោកអ្វីទៀតទេ! គឺត្រូវធ្វើជាម្ចាស់នៃភាគហ៊ុនជាមួយរបប ហ៊ុន សែន តែម្តងទៅ! វាស្រ្តហាត់នឹងការបោកប្រាស់របស់លោកខ្លាំងណាស់ហើយ។ ហ្នឹងហើយដែលជា"ជ័យជំនះ" បានមកដោយភាពស្មោះត្រង់នឹង"បច្ចាមិត្ត"របស់ខ្លួនឯងនោះ។

តមកពីទំព័រទី ០២

## កាលីហ្វ័រញ៉ា...

ចំពោះផលិតផលសម្លៀកបំពាក់, កាបូបយួរដៃ, ស្បែកជើង, ស្បែកជើងប្រភេទសម្រាប់ពាក់នៅផ្ទះ, មួក ឬខ្សែសង្វាក់សំខាន់ៗដែលមានរោមសត្វ ហើយត្រូវរងនូវការពិន័យស៊ីវិល ចំពោះការល្មើសច្បាប់នីមួយៗ។" ច្បាប់ថ្មីនេះនឹងមិនបានរៀបបញ្ចូលប្រភេទស្បែក, ស្បែកគោ និងស្បែកចៀមនេះទេ។ គួរបញ្ជាក់ថា ច្បាប់ថ្មីនេះ នឹងនឹងចូលជាធរមាននៅឆ្នាំ២០២៣ ។

នៅក្នុងច្បាប់ដើម្បីហាមឃាត់ការលក់ផលិតផល រោមសត្វថ្មី បទបញ្ញត្តិនេះ ក៏មានចែងធ្វើការហាមឃាត់សត្វដែលត្រូវបាន ប្រើក្នុងការសម្តែងសៀកដូចជាដំរី, ខ្លាឃ្មុំ និងខ្លា និងហាមឃាត់ ការបរបាញ់, ការដាក់អន្ទាក់ ឬការសម្លាប់សត្វសត្វឆ្មាព្រៃនៅក្នុងរដ្ឋកាលីហ្វ័រ ញ៉ាផងដែរ។

លោកអភិបាលរដ្ឋ ញ៉ូសុម បាមានប្រសាសន៏ថា " រដ្ឋកាលី ហ្វ័រញ៉ា គឺជារដ្ឋដឹកនាំគេនៅពេលនិយាយអំពីសុខុមាលភាពសត្វ ហើយបច្ចុប្បន្ននេះការដឹកនាំរបស់យើងក៏រួមបញ្ចូលការហាមឃាត់ការលក់រោមសត្វ។" លោកក៏បានបន្ថែមទៀតថា "ប៉ុន្តែយើងកំពុងតែធ្វើលើសពីនេះទៅទៀត។ យើងកំពុងធ្វើសេចក្តីថ្លែងការណ៏ទៅកាន់ពិភពលោកថា សត្វព្រៃដ៏ស្រស់ស្អាត ដូចជា ខ្លាឃ្មុំ និងសត្វខ្លា មិនមានកន្លែងសម្រាប់ខ្សែរអន្ទាក់ ឬការលោតឆ្លងកាត់អណ្តាតភ្លើងទៀតទេ។ គ្រាន់តែយូធ្យូបវីដេអូដែលបង្ហាញពីវិធីដ៏ឃោរឃៅដែលសត្វទាំងនេះជារឿយៗត្រូវបានគេបំបែកចេញពីម្តាយរបស់ពួកវាពេលដែរនៅតូច ត្រូវបានបណ្តុះបណ្តាលឱ្យធ្វើការសម្តែងដែលមានគ្រោះថ្នាក់។ សកម្មភាពនេះគួរអោយកង្វល់ជាខ្លាំង"។










# DIVERSITY
## ADULT DAYCARE CENTER

*"A place where your loved ones can call home"*

**What is Adult Day Care:**

We understand that being a fulltime caregiver is a difficult job. When an elderly loved one needs additional care or supervision during the morning or day, it can create stress for the caregivers of the family. Many families think they have no choice but to quit their jobs or to admit their loved ones into a nursing home or assisted living facility. Diversity Adult Daycare Center (DADC) provides a safe supervised community where elderly adults can socialize, enjoy activities and get assistance with personal care. This will allow the caregivers of the family to have peace of mind when they have an appointment, work obligations or simply to enjoy some personal time.

**Benefits of Adult Day Care for Elderly Adults:**

Attending Adult Day Care has many positive benefits for elderly adults. Your loved ones do not have to be at home feeling lonely with no mental stimulation, when the caretakers are occupied. Being in an Adult Day Care creates a feeling of being in a community, where they can have fun and stay healthy with many activities. Your loved ones will look forward to having their independence and meeting their friends. Having friendships that you see every day promotes feelings of self-worth and camaraderie.

**Services we offer at DADC:**
- Nutritious meals and snacks
- Group fitness classes
- Education classes
- Group field trips and outings
- Fun daily entertainment and activities
- Assistance with personal care
- Salon service
- Transportation
- Monthly birthday parties
- Medical staff
- Gardening

**Who is an ideal candidate for Adult Day Care:**
- 55 years and older
- Southeast Asians & Hispanic
  (we are handicap accessible)

**Forms of payment that we accept:**
- We accept private pay
- All major insurances accepted

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818

# MRT Presents Cambodian Rock Band

## A Play By Lauren Yee

a co-production with Victory Gardens Theatre in Chicago and City Theatre in Pittsburgh

By KhmerPost USA

LOWELL, MA – Merrimack Repertory Theatre (MRT) will presents the East Coast Premiere of Cambodian Rock Band by Lauren Yee, directed by Marti Lyons and featuring the songs of Dengue Fever, Sinn Sisamouth, Voy Ho, and Ross Serey Sothea, from October 16 to November 10 at the Nancy L. Donahue Theatre.

Yee said, "Having these actors perform live was really the best way to celebrate what theatre does better than anything else, and also really give you a visceral sense of what this music felt like. It is particularly noteworthy that Cambodian music is not just covers of American or Western music. It's really this modern, distinctive sound that is found nowhere else . . . traditional Cambodian music, French New Wave, some of the Vietnam War-era radio."

Set in 1978, a father flees Cambodia's Khmer Rouge regime. Thirty years later, his daughter attempts to piece together her family history, kicking off the events of Cambodian





Rock Band, "a riveting play that's part mystery, part history lesson, and part unabashed jukebox musical concert," according to Broadway World. Rock Band celebrates the resilient bond of family through hardship and sacrifice and the enduring power of 70s music.

Award-winning, innovative Chinese-American playwright Lauren Yee is a San Franciscan, who currently resides in New York City. Cambodian Rock Band was named the winner of the Harold and Mimi Steinberg/American Theatre Critics Association New Play Award in 2018. Her plays, which have been performed throughout the world, include The Great Leap, The Song of Summer, King of the Yees, and The Hatmaker's Wife, an Outer Critics Circle Award nominee for Best American Play. Yee's plays have won the Horton Foote, Kesselring, and Francesca Primus prizes.

The cast of Cambodian Rock Band includes Eileen Doan (Pou, keyboards), Albert Park (Duch), Christopher Thomas Pow (Leng/Ted, guitar), Peter Sipla (Rom, drums), Greg Watanabe (Chum, bass), and Aja Wiltshire (Neary/Sothea, vocals).

For tickets to Cambodian Rock Band, call the MRT Box Office at 978-654-4678, or visit MRT.ORG. Tickets start at $24.







Congratulations to Veasna Noun, Sokhary Chou, and Ty Chum for their excellent finishes in the Primary Election. And congratulations to the Cambodian community for helping them.

**Jim Peters for School Committee**

សូមអបអរសាទរចំពោះលោក វាសនា នួន, សុខារី ឆៅ និង ទី ឈុម ដែលបានសម្រេចលទ្ធផលដ៏អស្ចារ្យក្នុងការបោះឆ្នោតបឋមជ្រើសរើសបេក្ខជន។ ហើយចូលរួមអបអរដល់សហគមន៍ខ្មែរចំពោះការជួយគាំទ្រពួកគាត់ **លោក ជីម ភីតធើរ បេក្ខជនសម្រាប់ការបោះឆ្នោតគណៈកម្មការសាលារៀន**



# Award-Winning Filmmaker to Screen New Documentary at MCC

By Caitlin Buckley, MCC

Lowell, MA — Cambodian American filmmaker Kalyanee Mam is coming to Lowell and will be hosted by Middlesex Community College for a screening of her documentary, "Lost World," on Saturday, November 2, from 6:30 to 7:30 p.m. at the Richard & Nancy Donahue Family Academic Arts Center, 240 Central St., Lowell. All are encouraged and welcome to attend this free screening!

Mam will discuss how communities must be held responsible and work together to protect the natural world from the cause and effects of climate change.

She said, "Many of our motives and beliefs come from a mistaken perception of the world and its values. By changing our definition of what it means to be powerful, beautiful and aware, we can make those who commit acts of injustice reflective and accountable for their actions."

Her inspiration for filming stems from a visit to the mangrove forests in Cambodia that she took with a friend.

"We sailed along the ocean for over an hour and yet, the mangrove forests continued to stretch on for miles, their shiny green leaves shimmering like water in the early evening light," Mam said.

As they ventured onwards, the tree line dwindled and Mam was appalled by what she discovered.

"Huge excavators were mining the mangrove forests for sand and shipping this sand to Singapore to expand this island nation's land mass, while the people and all the living creatures that depend on these forests for their livelihood, are forced to cope with this massive loss."



Cambodian-American filmmaker Kalyanee Mam

Mam was born in Cambodia, but her family left to escape the Khmer Rouge regime. Upon her return, she was disheartened to witness the destruction of her homeland.

"I wanted to understand where all this sand was going and why and how a country, considered one of the most affluent in the world, could destroy someone else's home to build their own," she said. "It is already enough to be removed from one's land. It is another thing entirely to have one's land removed as well."

Dr. Shelley Hawks, MCC Adjunct Professor of Art History, said, "Her filmmaking provides a great example of how visual forms of story-telling awaken us to threats to our environment. Her film nurtures concern for nature in this era when we must learn to value nature more and move towards environmental sustainability."

Mam directed and produced "A River Changes Course" in 2013, which won the Sundance Grand Jury Prize and is the cinematographer and associate producer of the Academy Award-winning film "Inside Job" in 2011.



"អត្ថបទស្រាវជ្រាវប្រវត្តិសាស្ត្រ"

# ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ

(KJA = Khmer Journalist Association )

ដោយ ពិន សំខុន **តពីលេខមុន**

នៅកំពង់ចាមខ្ញុំបានទៅសំណាក់នៅផ្ទះ តាមខ្ញុំគ្រប់ជំហ៊ានដើរតួរជាអង្គរក្សរបស់ខ្ញុំ, ទាំង ពនាក់យើងតែងធ្វើការគ្មានពេលវេលាគ្មានតួញត្អែរ នឹងគ្មានរួញរា ទោះជាទៅដល់ទីឆ្ងាយ





មិត្រអតីតកុមារយោធាម្នាក់ឈ្មោះ រឿម រុន ដោយមានប្អូនជីដូនម្នាក់ជាអ្នកជំនួយការបើកបររថយន្ត"កាមរី"មួយនឹងអតីតមេទ័ពអ្នកតស៊ូម្នាក់ទៀត ជាអតីតកុមាយោធាម្នាក់ ដែលទៅជិតណាក្តី យប់ព្រលប់ ឬទៅកន្លែងដែលគ្មានសុវត្ថិភាពក៏ដោយក្តី ក៏ទៅជាមួយគ្នា...។ នៅកម្ពុជា នាអម្លុងពេលឃោសនានយោបាយ ក្រៅពីគ្រោះថ្នាក់ ដោយការប្លន់ ចាឯកជន គ្រោះថ្នាក់ដោយការសង្ស័យពីក្រុមសកម្មជនគណបក្សប្រជាជនដែលមិនបានទម្លាក់អាវុធតាមអត្ថន័យនៃកិច្ចព្រមព្រៀង, នៅមានក្រុមខ្មែរក្រហម ក៏មិនព្រមទម្លាក់អាវុធដូចគ្នា ហើយនៅវាយគ្នាបង្ករជាអសន្តិសុខជាច្រើនកន្លែងនាពេលឃោសនាទៀតផង។

នៅកំពង់ចាម យើងមានទីស្នាក់ការមួយសមរម្យ ជាផ្ទះរបស់សមាជិកម្នាក់ឈ្មោះ សេង នៅភូមិមេម៉ាយ ទុកជូនលោកតា អ៊ិន តាំ ដែលជាគ្រួសារ ក៏ជាបេក្ខជនម្នាក់ដែរ ។ នៅកំពង់ចាមនោះ គឺជាសំបុកគ្រួសារដ៏ធំរបស់លោក អ៊ិន តាំ តាំងពីកោះសូទិន ជីហែរ ព្រៃទទឹង ពាមជីកង... ។ល ។យើងបានប្រើទីស្នាក់ការក្រុងកំពង់ចាម ជាទីប្រជុំ ឬទទួលសមាជិកស្រុកជិតឆ្ងាយមិនដែលដាច់...ធ្វើឱ្យកំពង់ចាមក្លាយជាទីសង្ឃឹមដ៏សំខាន់មួយហើយលោកអ៊ិនតាំក៏ប្តូរបេក្ខភាពពីតំបន់ភ្នំពេញ( មាន១២អាសនៈ) មកឈរនៅកំពង់ចាមវិញម្តង( មាន១៨អសនៈ) ។ ខ្ញុំបានជួបលោក អ៊ុង វីទ្ធី ជាលើកដំបូងនៅភ្នំពេញ ជាបេក្ខជនទៅពីឡូវែលសហរដ្ឋអាមេរិក ទៅឈរជើងនៅតាកែវ, លោក អ៊ុក ភូរីក ជាអនុប្រធាននឹងជាបេក្ខជនទៅពីប៉ារីសដូចខ្ញុំដែរ ឈរជើងនៅភ្នំពេញ...។ **តទៅលេខក្រោយ**












# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

**ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។**

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយ ថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយ គ្រូពេទ្យ និងខេសម៉ានីជើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ដើម្បីចុះឈ្មោះសូមទាក់ទងមក
## To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# វត្ថុបុរាណខ្មែរ រឹបអូសបាននៅសាន់ហ្វាន់ ស៊ីស្កូ

ដោយខ្មែរផុស ស.រ.អា

អាមេរិក - កាលពីថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៩ កន្លងទៅនេះ ភ្នាក់ងារស៊ើបអង្កេតផ្នែកសន្តិសុខមាតុភូមិនៃនាយកដ្ឋានពង្រឹងច្បាប់អន្តោប្រវេសន៍ និងគយរបស់សហរដ្ឋអាមេរិក បានរឹបអូសរូបដិមាបុរាណខ្មែរពីទីតាំងដាក់លក់ដេញថ្លៃមួយកន្លែងនៅទីក្រុងសាន់ហ្វាន់ស៊ីស្កូរ ដែលមានតំលៃប្រមាណជា៣៥០,០០០ដុល្លារ។



រូបចម្លាក់ដែលរឹបអូសបាននោះ ត្រូវបានគេពិពណ៌នាថា ជាបដិមាតំណាងឱ្យព្រះសិវៈ និងព្រះនាងឧមាធ្វើពីថ្មភ្លុកក្នុងចន្លោះ ឆ្នាំ៩២១-៩៤៥ នៃគ្រិស្តសករាជ ហើយគ្រោងនឹងដឹកជញ្ជូនទៅកាន់ប្រទេសកម្ពុជាវិញបន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតទាំងស្រុងដែលដឹកនាំដោយភ្នាក់ងារស៊ើបអង្កេតសន្តិសុខមាតុភូមិប្រចាំទីក្រុងញូវយ៉ក។

រូបចម្លាក់នេះ ត្រូវបានទិញដោយអ្នកប្រមូលវត្ថុបុរាណឯកជនមួយម្នាក់នៅក្នុងក្រុងសាន់ហ្វ្រាន់ស៊ីស្កូរ ហើយបានដាក់លក់ដេញថ្លៃបន្ទាប់ពីអ្នកទិញនេះបានស្លាប់កាលពីឆ្នាំ២០១៥។ បើយោងតាមសេចក្តីប្រកាសព័ត៌មាននាយកដ្ឋានពង្រឹងច្បាប់អន្តោប្រវេសន៍ និងគយ ការបានឱ្យដឹងថា ការស៊ើបអង្កេតនេះ គឺផ្តោតទៅលើសកម្មភាពរត់ពន្ធរបស់លោក ឌូក្លាស ឡឺតហ្វដ ( Douglas Latchford) ដែលជាអ្នកប្រមូលវត្ថុបុរាណឯកជន ដែលជាប់ពាក់ព័ន្ធទៅនឹងវត្ថុបុរាណរបស់ខ្មែរដែលត្រូវបានគេលួចជាច្រើន។


ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនស្វ៊ិរិន អេជេនស៊ី

KK Insurance Agency, Inc.

រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម

Car • Home • Business

508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com





ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration • អន្តោប្រវេសន៍
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com



We make health care easy

Neighborhood has affordable plans for:
- Children and families
- Individuals
- Small businesses

យើងធ្វើឲ្យការថែទាំសុខភាពងាយស្រួល

Neighborhood មាន
គម្រោងដែលមានតម្លៃសមរម្យសម្រាប់៖
- កុមារ និងក្រុមគ្រួសារ
- បុគ្គលម្នាក់ៗ
- អាជីវកម្មខ្នាតតូច

Neighborhood Health Plan OF RHODE ISLAND™

Contact us today to learn more!
សូមទាក់ទងមកយើងខ្ញុំនៅថ្ងៃនេះ:
ដើម្បីស្វែងយល់បន្ថែម!
www.nhpri.org



LEGEND
MOTOR GROUP, INC.

ហាងជួលជុលរថយន្ត លេជេន

មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ ?

ទូរស័ព្ទ 978-458-2085

COLLISION REPAIR

BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.





យើងរៀបចំសណ្តោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹង
ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង។

115 Rock St. Unt #7 Lowell, MA 01854


NOW PLAYING
CAMBODIAN ROCK BAND
A father's secret.
A daughter's love.
NOW – NOV 10
by Lauren Yee
directed by Marti Lyons
songs by Dengue Fever
"A FIERCE, GORGEOUS, COMEDIC FAIRY TALE!"
– LOS ANGELES TIMES
MRT
MERRIMACK REPERTORY THEATRE
50 EAST MERRIMACK ST LOWELL, MA
MRT.ORG | 978-654-4678
ក្រុមជន្រ្តី ប៉េន រ៉ុក ខាំបូឌា
CAMBODIAN ROCK BAND
ថ្ងៃទី 16 ខែតុលា ឆ្នាំ 2016 - East Coast Premiere
ដោយ ឡូរេន យី (Lauren Yee)
ដឹកនាំដោយ ម៉ាទី ឡៃន (Marti Lyons)
ច្រៀងដោយក្រុមជន្រ្តី Dengue Fever
រួមបន្ថែមនឹងចម្រៀងរបស់លោក ស៊ិន ស៊ីសាមុត, រ៉ុស ស៊ែរ៉ី សុធា
យោងតាមសារព័ត៌មាន Broadway World, ក្នុងឆ្នាំ 1978 លោកឪពុក រត់គៀសខ្លួនចេញពីរបបខ្មែរក្រហមក្នុងប្រទេសកម្ពុជា។ 30 ឆ្នាំក្រោយមក កូនស្រីរបស់លោក ព្យាយាមជួបជុំគ្នាគ្រួសាររបស់អ្នកនាងជាប្រវត្តិសាស្ត្រ ដោយបានរៀបចំនូវកម្មវិធីជាច្រើនដែលមានឈ្មោះថា Cambodian Rock Band ជាកម្មវិធីសម្ដែងគួរឲ្យចាប់អារម្មណ៍ដែលជាចំណែកមួយនៃរឿងភាពយន្តដោយអាថ៌កំបាំង, ជាចំណែកមួយនៃមេរៀនប្រវត្តិសាស្ត្រ និងជាចំណែកមួយនៃការប្រគុំតន្ត្រីដែលមានបទចម្រៀងបង្កប់ទៅដោយរឿងរ៉ាវ។ ក្រុមជន្រ្តី Rock Band អបអរសាទរចំពោះចំណងគ្រួសារដ៏រឹងមាំ តាមរយៈការទិតទំប្រឹងប្រែង, និងការលះបង់ ហើយបន្តលើកស្ទួយបទចំរៀងដ៏អស្ចារ្យនៅកំឡុងទសវត្សទី ៧០ ។
បើតាមការសែត Los Angeles Times - "រឿងរ៉ាវដ៏អាក្រក់, គួរឲ្យទាក់ទាញ, សប្បាយរីករាយ និងកំប្លែង។ អ្នកនាង យី បានប្រែក្លាយចរិតលក្ខណៈរបស់អ្នកនាងជាមនុស្សដែលមានភាពរីករាយ និងគួរឲ្យអស់សំណើចដែលពិបាកក្នុងការកំណត់ណាស់" -
សំបុត្រ 2 សន្លឹកតម្លៃ $40
ទូរស័ព្ទឥឡូវនេះ! 978-654-4678
ចូលទៅកាន់គេហទំព័រ MRT.ORG
PLEASE NOTE:
Dialogue primarily in English; some songs in Khmer.
circlehealth
Complete connected care
SEASON SPONSOR